# បញ្ញត្តិ និងលក្ខខណ្ឌសម្រាប់ប័ណ្ណឥណពន្ធ ឯកត្តជន
# TERMS & CONDITIONS OF INDIVIDUAL DEBIT CARD

## 1. សេចក្តីផ្តើម / Introduction

១.១ បញ្ញត្តិ និង លក្ខខណ្ឌទាំងអស់នេះនឹងត្រូវបានយកទៅអនុវត្តចំពោះការប្រើប្រាស់ប័ណ្ណឥណពន្ធរបស់ធនាគារ អ៊ូរី។ លក្ខខណ្ឌទាំងនេះ ត្រូវបានបង្កើតឡើងសម្រាប់ប្រើអមជាមួយឯកសារ "តារាងកម្រៃសេវា និងលក្ខខណ្ឌផ្សេងៗនៃផលិតផលប័ណ្ណរបស់ធនាគារ" និងប័ណ្ណផ្សព្វផ្សាផ្សេងទៀតនៃសេវាកម្ម។ លោកអ្នកត្រូវរក្សាទុកឯកសារនេះសម្រាប់ជាឯកសារយោងក្នុងកំឡុងពេលនៃការប្រើប្រាស់ផលិតផលប័ណ្ណរបស់ធនាគារ។

១.២ បញ្ញត្តិនិងលក្ខខណ្ឌនៃការប្រើប្រាស់ប័ណ្ណឥណពន្ធត្រូវបានអាននិងយល់ដឹងនៅមុនពេលប្រើប្រាស់ប័ណ្ណឥណពន្ធរបស់ធនាគារ ហើយបញ្ញត្តិ និងលក្ខខណ្ឌនៃការប្រើប្រាស់ ប័ណ្ណឥណពន្ធនេះជាកិច្ចសន្យាដែលចងភ្ជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ រវាងម្ចាស់ប័ណ្ណ និងធនាគារ។ ការប្រើប្រាស់ ឬការធ្វើប្រតិបត្តិការលើកដំបូងនៃប័ណ្ណឥណពន្ធត្រូវបានចាត់ទុកថាម្ចាស់ប័ណ្ណបានអានបានយល់និងបានយល់ព្រមទទួល អនុវត្តតាមបញ្ញត្តិ និងលក្ខខណ្ឌនៃការប្រើប្រាស់ប័ណ្ណឥណពន្ធនេះ។

១.៣ ធនាគារ អាចកែប្រែគ្រប់ពេលនូវ "បញ្ញត្តិ និងលក្ខខណ្ឌ" និង "តារាងកម្រៃសេវា និងលក្ខខណ្ឌផ្សេងៗនៃប័ណ្ណឥណពន្ធ" ដោយអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ លើកលែងតែមានចែងក្នុងកិច្ចសន្យា យើងនឹងជូនដំណឹងទៅលោកអ្នកអំពីការកែប្រែ ក្នុងករណីដែលការកែប្រែនោះ ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់លោកអ្នក។

១.៤ ក្នុងបញ្ញត្តិ និងលក្ខខណ្ឌនេះ ពាក្យ "អ្នក", "លោកអ្នក", "របស់លោកអ្នក", និង "ម្ចាស់ប័ណ្ណ" គឺសំដៅដល់អតិថិជនដែលប្រើប្រាស់ប័ណ្ណឥណពន្ធរបស់ធនាគារ អ៊ូរី។ ពាក្យ "យើង", "របស់យើង", និង "ធនាគារ", គឺសំដៅដល់ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក។

1.1 These terms and conditions are applicable to the use of Woori Bank debit card. These conditions designed for using with "Fees & Limitations of Woori card" and other service brochures. You should keep this document for future reference during period of card service using.

1.2 The debit card terms and conditions shall be read and understood before using the bank's debit card and is a legally binding contract between the cardholder and the bank. First use/transaction under the debit card implies that the cardholder has fully read, understood and accepted the debit card terms and conditions.

1.3 The bank may change these "terms and conditions" and "fee & charge and other conditions of debit card" at any time subject to applicable law of Cambodia. Except as indicated herein, we will inform you of changes that affect your rights and obligations.

1.4 Throughout this publication, the words "you", "your", "yours" and "cardholder" refer to the customer using Woori Bank debit card. The word "we", "us", "our", "Woori Bank" and "the bank" refer to Woori Bank (Cambodia) Plc.

## 2. និយមន័យ / Definition

២.១ ម្ចាស់ប័ណ្ណ គឺជាបុគ្គល ឬនីតិបុគ្គលដែលជាម្ចាស់ប័ណ្ណប្រភេទណាមួយដែលចេញដោយធនាគារ។

២.២ លេខសម្ងាត់ (PIN) គឺជាលេខសម្ងាត់ប្រាំមួយខ្ទង់ដែលចេញដោយធនាគារ ដល់ម្ចាស់ប័ណ្ណ ដើម្បីប្រើប្រាស់ប័ណ្ណ ធ្វើប្រតិបត្តិការហិរញ្ញវត្ថុ ឬប្រតិបត្តិការទូទៅដែលផ្អែកលើលេខ កូដសម្ងាត់ នៅលើម៉ាស៊ីនអេធីអឹម និងម៉ាស៊ីនឆូតកាត។

២.៣ ពាណិជ្ជករ មានន័យថាជាពាណិជ្ជករណាម្នាក់ ដែលផ្គត់ផ្គង់ទំនិញ និង/ឬ សេវាកម្ម។

២.៤ ប្រតិបត្តិការប័ណ្ណ គឺជាការប្រើប្រាស់ប័ណ្ណដើម្បីទូទាត់ទៅលើទំនិញ និង/ឬសេវាកម្ម ឬការដកសាច់ប្រាក់ពីម៉ាស៊ីន ATM ពីធនាគារ ឬស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត។

២.៥ ម៉ាស៊ីនអេធីអឹម មានន័យថាម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិរបស់ធនាគារឬគ្រឹះស្ថានហិរញ្ញវត្ថុដទៃទៀត។

២.៦ អ្នកចេញប័ណ្ណ សំដៅលើ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក រួមបញ្ចូលទាំងសាខាដែលកំពុងធ្វើប្រតិបត្តិការរបស់ ធនាគារ អ៊ូរី (ខេមបូឌា) ម.ក។

២.៧ កម្រិតកំណត់ប្រតិបត្តិការប្រចាំថ្ងៃ សំដៅលើចំនួនទឹកប្រាក់អតិបរមាដែលធនាគារ អនុញ្ញាតឱ្យម្ចាស់ប័ណ្ណធ្វើប្រតិបត្តិការក្នុងមួយថ្ងៃ។

2.1 Cardholder is a person or a legal entity who owns any type of cards issued by the bank.

2.2 PIN (Personal Identification Number) is a secret six-digit number issued by the bank to cardholder to use with debit card performing PIN-based transaction at chip POS and ATM terminal.

2.3 Merchant means any merchant who is supplying goods and/or service;

2.4 Card transaction is the use of the card to pay for goods and/or service or to withdraw cash from an ATM, bank or other financial institution.

2.5 ATM means an automated teller machine belonging to the bank or to other financial institution.

2.6 Card issuer refers to Woori Bank (Cambodia) Plc. including all of its operating branches.

2.7 Daily limit means the maximum permissible limit prescribed by the bank in respect of the total transactions effected in a day.

## 3. ហត្ថលេខានៅលើប័ណ្ណ / Signature on the card

៣.១ នៅពេលទទួលបានប័ណ្ណ ម្ចាស់ប័ណ្ណត្រូវចុះ ហត្ថលេខាភ្លាមៗនៅលើប័ណ្ណ (ដោយប្រើហត្ថលេខាដែលដូចគ្នាទៅនឹងហត្ថលេខា ដែលបង្ហាញនៅក្នុងពាក្យស្នើសុំប្រើប្រាស់ប័ណ្ណ) និងនៅលើឯកសារ/លិខិតស្តីពីការទទួលស្គាល់នៃការទទួលបានណាមួយដែលតម្រូវដោយធនាគារនិងត្រូវធ្វើការបញ្ជូនត្រលប់មកកាន់ធនាគារវិញនូវឯកសារទាំងនោះ។ហត្ថលេខារបស់ម្ចាស់ប័ណ្ណនៅលើប័ណ្ណឬនៅលើរបាយការណ៍ទិញទំនិញ របាយការណ៍ប្រតិបត្តិការសក្ខីប័ត្រឥណទាន របាយការណ៍ដកប្រាក់ និង/ឬរបាយការណ៍ស្តីពីបន្ទុកផ្នែកហិរញ្ញវត្ថុ និង/ឬការប្រើប្រាស់ប័ណ្ណ និង/ឬការបញ្ជូនត្រលប់មកវិញនូវឯកសារ/លិខិតស្តីពីការទទួលស្គាល់នៃការទទួលបាននឹងបង្កើតជាភស្តុតាងចងភ្ជាប់ និងគ្មានមន្ទិលដែលបញ្ជាក់អំពីការបង្កើតកិច្ចព្រមព្រៀងនេះរវាងម្ចាស់ប័ណ្ណជាមួយនឹងធនាគារ។

3.1 Upon the receipt of the card, the cardholder shall immediately sign on the card (using the same signature as that appearing on the application form of the card) and on any acknowledgement of receipt required by the bank and return such acknowledgement of receipt to the bank. The signature of the cardholder on the card or on any sales draft, transaction record, credit voucher, cash disbursement draft and/or other financial charge record and/or the use of the card and/or return of the acknowledgement or receipt will constitute binding and conclusive evidence of the cardholder entering into this agreement with the bank.

## 4. ការដាក់ឱ្យដំណើរការប័ណ្ណ / Card Activation

៤.១ ធនាគារ នឹងចេញលេខកូដសម្ងាត់ផ្ទាល់ខ្លួន(PIN)ជូនម្ចាស់ប័ណ្ណ សម្រាប់ប្រើប្រាស់ជាមួយប័ណ្ណដែលធ្វើប្រតិបត្តិការដោយលេខកូដសម្ងាត់ផ្ទាល់ខ្លួន (PIN) នៅតាមម៉ាស៊ីនអេធីអឹម ឬម៉ាស៊ីនផ្សេងៗដែលមានមុខងារសម្រាប់ប្រើប្រាស់ជាមួយប័ណ្ណជាក់លាក់ណាមួយ។

៤.២ ធនាគាររក្សាសិទ្ធិបញ្ឈប់ដំណើរការប័ណ្ណ ប្រសិនបើម្ចាស់ប័ណ្ណមិនបានមកទទួលយកប័ណ្ណក្នុងរយៈពេលបី(៣)ខែ គិតចាប់ពីកាលបរិច្ឆេទចេញប័ណ្ណ។

៤.៣ ប្រសិនបើម្ចាស់ប័ណ្ណជឿថាលេខកូដសម្ងាត់ផ្ទាល់ខ្លួន(PIN)ត្រូវបានដឹងដោយបុគ្គលណាម្នាក់នោះម្ចាស់ប័ណ្ណ ត្រូវទាក់ទងមកកាន់ធនាគារភ្លាម តាមដែលអាចធ្វើទៅបាន។

៤.៤ ម្ចាស់ប័ណ្ណ ត្រូវទទួលខុសត្រូវចំពោះរាល់ការធ្វើប្រតិបត្តិការទាំងអស់ ដែលត្រូវបានធ្វើឡើង ដោយការប្រើប្រាស់ប័ណ្ណឥណពន្ធទោះបីប្រតិបត្តិការនោះត្រូវបានធ្វើឡើងដោយមានឬគ្មានការអនុញ្ញាតឬដឹងឮដោយម្ចាស់ប័ណ្ណក៏ដោយ។

4.1 A PIN will be issued by the Bank to Cardholder to use with the respective Card performing PIN-based transaction at the ATM terminals or other machines as available under functional specifications of each Card.

4.2 The bank reserves the right to cancel the card if it has not been collected by you for more than three (3) months after the issuing date.

4.3 If the Cardholder believes that someone may have discovered the PIN, the Cardholder is required to contact the bank immediately and as soon as practicable.

4.4 The cardholder is liable for all debit card transactions affected by the use of the debit card whether or not such use is authorized by or known to the cardholder.

## 5. ប្រភេទប័ណ្ណឥណពន្ធ / Debit Card Type

៥.១ ម្ចាស់ប័ណ្ណ អាចដាក់ពាក្យស្នើសុំ ដូចដែលត្រូវបានកំណត់ដោយធនាគារ ដោយអនុលោមតាមបញ្ញត្តិនិងលក្ខខណ្ឌនៃការប្រើប្រាស់ប័ណ្ណនេះ ដូចខាងក្រោម៖
(ក) ប័ណ្ណឥណពន្ធវីសាក្លាស៊ីកសម្រាប់បុគ្គល
(ខ) ប័ណ្ណឥណពន្ធវីសាផ្លាទីនីមសម្រាប់បុគ្គល

5.1 The Cardholder may submit the Application as prescribed by the Bank in accordance with these terms and conditions to request the following cards:
(A) Visa Debit Classic for individual customer
(B) Visa Debit Platinum for individual customer

៥.២ ប័ណ្ណឥណពន្ធ មានសុពលភាពក្នុងការប្រើប្រាស់រយៈពេលប្រាំ (៥) ឆ្នាំចាប់ពីថ្ងៃចេញប័ណ្ណ។

5.2 Debit card have 5-year validity period from issuance.

៥.៣ ធនាគារ មានឆន្ទានុសិទ្ធិ ក្នុងការចេញប័ណ្ណឥណពន្ធ ជូនម្ចាស់ប័ណ្ណប្រើប្រាស់ ឬបដិសេធពាក្យស្នើសុំប្រើប្រាស់ប័ណ្ណរបស់ម្ចាស់ប័ណ្ណ។

5.3 Woori Bank, at its sole discretion, may issue debit cards for the use of the cardholder or to reject the application for the cards.

## 6. ប្រតិបត្តិការទិញទំនិញ (ទំនិញ/សេវាកម្ម) / Sale Transaction (Goods/Service)

៦.១ ម្ចាស់ប័ណ្ណ អាចប្រើប្រាស់ប័ណ្ណដើម្បីធ្វើប្រតិបត្តិការទិញទំនិញ នៅក្នុងហាងរបស់ពាណិជ្ជករណាមួយ។ ម្ចាស់ប័ណ្ណ ត្រូវផ្តល់ព័ត៌មានឱ្យបានត្រឹមត្រូវតាមការស្នើសុំរបស់ធនាគារ សម្រាប់គោលបំណងអនុញ្ញាតលើប្រតិបត្តិការរបស់ធនាគារ។ ធនាគារ មានសិទ្ធិដកឥណពន្ធពីគណនីប័ណ្ណតាមចំនួនទឹកប្រាក់ ដែលម្ចាស់ប័ណ្ណបានធ្វើប្រតិបត្តិការ។

6.1 The cardholder may use the Card to make Sales Transaction(s) with any merchant. The Cardholder must provide duly needed accurate information, as the bank requires for transaction approval. The bank has the right to debit the card account with any transaction amount conducted by the cardholder.

៦.២ ម្ចាស់ប័ណ្ណប្រើប័ណ្ណដើម្បីទិញទំនិញ ឬសេវាកម្មតាមរយៈគេហទំព័រអនឡាញ ឬគេហទំព័រណាមួយ ម្ចាស់ប័ណ្ណត្រូវទទួលខុសត្រូវទាំងស្រុងចំពោះសុវត្ថិភាពក្នុងការប្រើប្រាស់នោះគ្រប់ពេលវេលា។ម្ចាស់ប័ណ្ណយល់ស្របថាការបញ្ចូលព័ត៌មាននៃប័ណ្ណទៅក្នុងអ៊ីនធើណេតនឹងត្រូវចាត់ទុកជាភស្តុតាងគ្រប់គ្រាន់នៃភាពត្រឹមត្រូវក្នុងការណែនាំឱ្យមានប្រតិបត្តិការនោះ។ ធនាគារ មិនមានកាតព្វកិច្ចផ្ទៀងផ្ទាត់អត្តសញ្ញាណ ឬ ឬសិទ្ធិរបស់បុគ្គលណាម្នាក់ ដែលបានបញ្ចូលព័ត៌មាននៃប័ណ្ណរបស់ម្ចាស់ប័ណ្ណឡើយហើយធនាគារមិនទទួលខុសត្រូវចំពោះការធ្វើសកម្មភាពនៃការប្រើប្រាស់ព័ត៌មាននៃប័ណ្ណឡើយ ដោយមិនគិតថាតើបុគ្គលណា ដែលត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការ ហើយក៏មិនគិតពីស្ថានភាពដែលត្រូវអនុវត្តក្នុងពេលនៃប្រតិបត្តិការនេះឡើយ។

6.2 Cardholder uses the card to purchase goods or services through online internet sites or portals, cardholder shall be solely responsible for the security of such use at all times. Cardholder agrees that the entry of the card information on the internet shall be sufficient proof of the authenticity of such transaction instructions. The bank shall not be under any obligation to verify the identity or the authority of the person entering the cardholder's card information and the bank shall not be liable for action on such use of the card information regardless of whether the person is so authorized and regardless of the circumstance prevailing at the time of transaction.

៦.៣ ធនាគារ មិនទទួលខុសត្រូវចំពោះគុណភាព ឬការបញ្ជូនទំនិញ ឬសេវាកម្មដែលបានធ្វើការទូទាត់តាមរយៈប្រតិបត្តិការទិញឡើយ។ រាល់វិវាទទាំងអស់ដែលទាក់ទងនឹងប្រតិបត្តិការទិញជាបញ្ហារវាងម្ចាស់ប័ណ្ណ និងពាណិជ្ជករតែប៉ុណ្ណោះ។

6.3 The bank is not responsible for the delivery or quality of goods or services paid through sales transaction. Any and all disputes related thereto are solely between the cardholder and the merchant.

៦.៤ ម្ចាស់ប័ណ្ណត្រូវទទួលខុសត្រូវរាល់ការទាមទារ ការទូទាត់ និងបញ្ហាពាក់ព័ន្ធនានាដោយផ្ទាល់ជាមួយពាណិជ្ជករ។

6.4 The cardholder is responsible for all claims, settlements and any other related matters directly with the Merchant.

៦.៥ ម្ចាស់ប័ណ្ណត្រូវទទួលខុសត្រូវទាំងស្រុង ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ ហើយទោះបីជាមាន ឬគ្មានចំណេះដឹងក្នុងការប្រើប្រាស់ ឬការធ្វើប្រតិបត្តិការណាមួយដែលប៉ះពាល់ដល់ប្រតិបត្តិការប័ណ្ណក៏ដោយ។

6.5 The cardholder shall be fully responsible under no circumstances and whether with or without knowledge, use or allow the use of the card to affect any card transaction.

## 7. ប្រតិបត្តិការសាច់ប្រាក់ / Cash Transaction

៧.១ ម្ចាស់ប័ណ្ណ អាចធ្វើប្រតិបត្តិការសាច់ប្រាក់តាមរយៈគ្រឹះស្ថានទទួលការទូទាត់ (គ្រឹះស្ថានដែលមានការសហការ ចុះកិច្ចព្រមព្រៀងជាមួយវីសា)។ សម្រាប់ព័ត៌មានបន្ថែមអំពីប្រតិបត្តិការដកប្រាក់ សូមមើលលើខិត្តប័ណ្ណព័ត៌មានស្តីអំពីថ្លៃសេវាកម្មនិងកម្រៃផ្សេងៗ។រាល់ប្រតិបត្តិការដកប្រាក់ទាំងអស់ដែលធ្វើឡើងតាមរយៈប័ណ្ណត្រូវធ្វើឡើងដោយម្ចាស់ប័ណ្ណតែម្នាក់គត់។ម្ចាស់ប័ណ្ណលះបង់សិទ្ធិទាមទារការបង្ហាញឯកសារគាំទ្រ ដែលទាក់ទងនឹងប្រតិបត្តិការណាមួយរបស់ប័ណ្ណ និងទទួលស្គាល់ថារបាយការណ៍របស់ធនាគារ ត្រូវបានសន្មតថាត្រឹមត្រូវ។

7.1 The cardholder may avail of cash transaction through settlement organizations, please refer to the fees and charges brochure for full details on cash transaction, it is understood and agreed that all cash transactions made with the card shall solely be made by a cardholder, the cardholder hereby expressly waives the presentation of any supporting document in relation to any card transaction, and acknowledges that the records of the bank are conclusively presumed to be correct,

៧.២ ធនាគារ រក្សាសិទ្ធិក្នុងការកម្រិតចំនួនទឹកប្រាក់របស់ប្រតិបត្តិការដកប្រាក់នីមួយៗ ឬចំនួនទឹកប្រាក់សរុបនៃប្រតិបត្តិការដកប្រាក់តាមរយៈប័ណ្ណក្នុងមួយថ្ងៃទៅចំនួនទឹកប្រាក់ដែលបានកំណត់ឬដែលបានកែប្រែតាមឆន្ទានុសិទ្ធិរបស់ធនាគារ ដោយមិនចាំបាច់ជូនដំណឹងទុកជាមុនដល់ម្ចាស់ប័ណ្ណ។

7.2 The bank reserves the right to limit the value of each cash transaction or the total amount of all cash transaction on the card in a day, without prior notice to the cardholder, to an amount determined and/or amended at the bank's sole discretion.

## 8. កម្រៃសេវា / Fees and Charges

៨.១ ម្ចាស់ប័ណ្ណ ត្រូវបង់នូវរាល់កម្រៃសេវាទាំងឡាយដែលទាក់ទងនឹងការប្រើប្រាស់ប័ណ្ណឥណពន្ធ រួមបញ្ចូលតែមិនកម្រិតត្រឹម កម្រៃសេវាដូចខាងក្រោម ("កម្រៃសេវាធនាគារ")៖
(ក) កម្រៃសេវាប្រើប្រាស់ប័ណ្ណឥណពន្ធប្រចាំឆ្នាំ ដែលត្រូវគិតថ្លៃមួយឆ្នាំម្តង ហើយត្រូវអនុវត្តចំពោះម្ចាស់ប័ណ្ណ លុះត្រាតែមានការលើកលែងផ្សេងពីនេះ ដោយធនាគារ។ កម្រៃសេវាប្រើប្រាស់ប័ណ្ណឥណពន្ធប្រចាំឆ្នាំនេះ ត្រូវបានកំណត់ និងប្រកាសដោយធនាគារ ដោយពុំចាំបាច់មានការជូនដំណឹងជាមុនដល់ម្ចាស់ប័ណ្ណឡើយ ហើយអាចធ្វើការ ផ្លាស់ប្តូរគ្រប់ពេលវេលា អាស្រ័យទៅតាមឆន្ទានុសិទ្ធិតែមួយគត់របស់ធនាគារ។ ធនាគារ អាចគិតកម្រៃសេវាលើការបន្តសារជាថ្មី និង/ឬ សេវាលើការដាក់ឱ្យប្រើប្រាស់ប័ណ្ណឥណពន្ធឡើងវិញ ទៅតាមឆន្ទានុសិទ្ធិតែមួយគត់របស់ខ្លួន ដោយមិនចាំបាច់ធ្វើការជូនដំណឹងជាមុនទៅកាន់ម្ចាស់ប័ណ្ណឡើយ។រាល់កម្រៃសេវាប្រើប្រាស់ប័ណ្ណឥណពន្ធប្រចាំឆ្នាំដែលបានទូទាត់រួច មិនអាចដកវិញបានឡើយ ទោះបីជាប័ណ្ណឥណពន្ធត្រូវបានព្យួរ ឬ បញ្ឈប់ការប្រើប្រាស់ ឬ ត្រូវបានបោះបង់ចោលដោយម្ចាស់ប័ណ្ណមុនកាលបរិច្ឆេទផុតកំណត់ក៏ដោយ។

8.1 The Cardholder must pay all fees and charges associated with the debit card including, but not limited to, the following fees ("Bank's Fees and Charges"):
(a). Annual fee of debit card will be charged once per year from cardholder, unless waived by the bank. This annual fee is fixed and announced by the bank and, without prior notice to the cardholder, is subject to change from time to time at the sole discretion of the bank. Renewal and/or reinstatement of the debit card and the fee thereof may be charged by the bank at its sole discretion and without prior notice to the Cardholder. All annual fees which have already been paid are non-refundable even if the debit card is suspended or terminated, or if the debit card is surrendered by the cardholder before the expiry date.

(ខ) កម្រៃសេវាដកសាច់ប្រាក់ នឹងត្រូវបានគិតថ្លៃ នៅពេលដែលម្ចាស់ប័ណ្ណដកប្រាក់ពីម៉ាស៊ីនអេធីអឹម ឬម៉ាស៊ីនឆូតកាត។

(b). Cash withdrawal fee will be charged when the cardholder withdraws cash from an ATM and POS.

(គ) កម្រៃសេវាប្តូររូបិយប័ណ្ណបរទេស នឹងត្រូវបានគិតថ្លៃ នៅពេលមានប្រតិបត្តិការប្តូររូបិយប័ណ្ណបរទេសដែលមិនមែនជារូបិយប័ណ្ណដុល្លារអាមេរិក អាស្រ័យទៅតាមប្រតិបត្តិការជារូបិយប័ណ្ណបរទេសនោះ និងពេលវេលាដែលប្រតិបត្តិការនោះ ត្រូវបានបង្ហាញទៅក្នុងគណនីប័ណ្ណឥណពន្ធ។

(c). Foreign currency conversion fee will be charged on the conversion of foreign currency transaction amount which is not United States Dollar, depending on the foreign transaction currency and on the time the transaction is posted to the debit card account.

(ឃ) កម្រៃសេវាបង់ត្រឡប់វិញដែលមិនត្រឹមត្រូវ នឹងត្រូវបានគិតថ្លៃ នៅពេលដែលម្ចាស់ប័ណ្ណស្នើសុំការបង់ត្រឡប់វិញដែលមានលក្ខណៈមិនត្រឹមត្រូវ តាមឆន្ទានុសិទ្ធិតែមួយគត់របស់ធនាគារ។

(d). Incorrect chargeback fee will be charged at the sole discretion of the bank when the Cardholder requests a chargeback that is assessed to be incorrect.

(ង) កម្រៃសេវាផ្លាស់ប្តូរប័ណ្ណឥណពន្ធថ្មី នឹងត្រូវបានគិតថ្លៃ នៅពេលដែលម្ចាស់ប័ណ្ណស្នើសុំផ្លាស់ប្តូរប័ណ្ណឥណពន្ធថ្មីមុនកាលបរិច្ឆេទផុតកំណត់ ឬ ដោយមូលហេតុបាត់បង់ ឬត្រូវបានគេលួច ឬខូចខាត។

(e). Debit card replacement fee will be charged when a cardholder requests a replacement of his/her debit card prior to the expiry date or due to lost/stolen or damage.

៨.២ ម្ចាស់ប័ណ្ណ ត្រូវមានទឹកប្រាក់គ្រប់គ្រាន់ ក្នុងការធ្វើប្រតិបត្តិការណាមួយ បើមិនដូច្នោះទេ ការស្នើសុំធ្វើប្រតិបត្តិការនឹងត្រូវបានបដិសេធ។

8.2 The cardholder must maintain sufficient funds for any transactions, otherwise the requested transaction(s) will be rejected.

៨.៣ ធនាគារមានសិទ្ធិក្នុងការធ្វើវិសោធនកម្ម ឬ ផ្លាស់ប្តូរកម្រៃសេវារបស់ធនាគារ ទៅតាមការយល់ឃើញសមរម្យរបស់ធនាគារ។ ធនាគារ នឹងជូនដំណឹងទៅកាន់ម្ចាស់ប័ណ្ណជាមុនអំពីការផ្លាស់ប្តូរកម្រៃសេវាណាមួយ តាមរយៈគេហទំព័ររបស់ធនាគារ ឬ តាមរយៈមធ្យោបាយទំនាក់ទំនងផ្សេងទៀតដែលអាចអនុវត្តបាន។

8.3 The bank has the right to amend or change the bank's fees and charges as it considers appropriate. The bank will notify the cardholder in advance via the bank's website or any other applicable means of communication of any change to the fees and charges.

៨.៤ ធនាគារ ត្រូវបានផ្តល់សិទ្ធិឱ្យកាត់ប្រាក់ចេញពីគណនីដែលត្រូវបានកំណត់របស់ម្ចាស់ប័ណ្ណ នូវចំនួនទឹកប្រាក់ទាំងអស់ ដែលបានកើតចេញពីការប្រើប្រាស់ប័ណ្ណ រួមបញ្ចូលទាំងការប្រើប្រាស់ប័ណ្ណដើម និងប័ណ្ណរង ដោយមិនគិតពីការព្យួរប័ណ្ណ ការបន្តការប្រើប្រាស់ប័ណ្ណ ការចេញប័ណ្ណថ្មី ឬការបញ្ចប់ការប្រើប្រាស់ប័ណ្ណ។

8.4 The bank is authorized to debit from the cardholder's designated account all amount resulting from the use of the card, including principal, and supplementary card regardless of suspension, renewal, replacement or termination of the card.

## 9. កម្រិតប័ណ្ណប្រចាំថ្ងៃ / Card Daily Limit

៩.១ ចំនួនទឹកប្រាក់ទាំងឡាយនៅក្នុងគណនីដែលត្រូវបានកំណត់ដែលបានភ្ជាប់ទៅនឹងប័ណ្ណអាចត្រូវបានប្រើប្រាស់ដោយម្ចាស់ប័ណ្ណ តាមរយៈម៉ាស៊ីនអេធីអឹម(ATM) ម៉ាស៊ីនឆូតកាត(POS) ឬប្រតិបត្តិការទិញតាមប្រព័ន្ធអនឡាញ ឬតាមបណ្តាញអនុវត្តដទៃទៀត ទៅតាមការអនុញ្ញាតរបស់ធនាគារ។ ប៉ុន្តែ ធនាគារ មានសិទ្ធិក្នុងការកំណត់ភាពញឹកញាប់ ឬចំនួនទឹកប្រាក់នៃការធ្វើប្រតិបត្តិការដែលរួមបញ្ចូលនិងមិនកម្រិតត្រឹមការទិញឬការដកប្រាក់("កម្រិតប្រចាំថ្ងៃ")។ ម្ចាស់ប័ណ្ណអាចស្នើសុំឱ្យធនាគារធ្វើការបង្កើន ឬបន្ថយកម្រិតប័ណ្ណប្រចាំថ្ងៃរបស់ប័ណ្ណ ដែលធនាគារបានចេញជូន ទៅតាមចំណាត់ថ្នាក់និងប្រភេទនៃប័ណ្ណដូចដែលត្រូវបានកំណត់តាមឆន្ទានុសិទ្ធិរបស់ធនាគារហើយធនាគារមានសិទ្ធិផ្តាច់មុខក្នុងការបដិសេធ ឬអនុម័តយល់ព្រមតាមសំណើសុំ។

9.1 Any amount in the designated account linked to the card is available for the cardholder's use via ATM, POS or online purchase transaction or other possible channels as permitted by the bank. However, the bank has the right to limit the frequency or amounts of transactions including, but not limited to, the purchase or the withdrawal ("daily limit"). The cardholder may request the bank to increase or decrease the daily limit of the card issued upon his/her card type rank in a prescribed for as determined by the bank and the bank, at its absolute discretion, is entitled to reject or grant such request.

## 10. ប័ណ្ណមិនត្រូវប្រើប្រាស់ក្នុងសកម្មភាពខុសច្បាប់ / Card Shall Not Be Used for Unlawful Activities

១០.១ ប័ណ្ណមិនត្រូវបានយកទៅប្រើប្រាស់ក្នុងសកម្មភាពខុសច្បាប់ ដូចជាប្រតិបត្តិការតាមប្រព័ន្ធអ៊ីនធើណេតខុសច្បាប់ និងការភ្នាល់ ឬល្បែងស៊ីសងខុសច្បាប់។

10.1 The Card shall not be used for any unlawful activities such as illegal online banking and betting or gambling.

១០.២ ធនាគារ ត្រូវបញ្ចប់ប័ណ្ណភ្លាមៗ ប្រសិនបើរកឃើញថាម្ចាស់ប័ណ្ណបានប្រើប្រាស់ប័ណ្ណក្នុងសកម្មភាពខុសច្បាប់។

10.2 The bank shall immediately terminate the card facility if the cardholders are found to have used the card for any unlawful activity.

## 11. ការការពារប័ណ្ណ និងលេខសម្ងាត់របស់លោកអ្នក / Protecting Your Card and PIN

១១.១ លេខសម្ងាត់ផ្ទាល់ខ្លួន (PIN) ត្រូវបានបង្កើតឡើងដោយស្វ័យប្រវត្តិចេញពីប្រព័ន្ធ និងផ្ញើទៅកាន់លេខទូរស័ព្ទអតិថិជនជាសារ (SMS)។ បន្ទាប់ពីទទួលបានលេខសម្ងាត់ដំបូង លោកអ្នកត្រូវបានលើកទឹកចិត្តឱ្យផ្លាស់ប្តូរលេខនោះ ហើយបង្កើតនូវលេខសម្ងាត់ផ្ទាល់ខ្លួនថ្មីមួយ ដោយប្រើលេខសុទ្ធប្រាំមួយ(៦)ខ្ទង់។

11.1 Personal Identification Number (PIN) is automatically generated by system and sent to your registered phone number as SMS after the card is activated. You are encouraged to change the first PIN after receiving and create your own one consisting of six (6) numeric digits.

១១.២ មិនត្រូវជ្រើសរើសលេខចេញពីលេខអត្តសញ្ញាណប័ណ្ណលេខទូរស័ព្ទថ្ងៃខែឆ្នាំកំណើតរបស់អ្នកឬលេខផ្សេងទៀតដែល គេដឹងជាទូទៅ និងងាយស្រួលទាយ មកធ្វើជាលេខសម្ងាត់ផ្ទាល់ខ្លួនឡើយ។

11.2 Do not choose the combination from your ID card number, phone number, or date of birth, or any number publicly known and easy to guess as your PIN.

១១.៣ ត្រូវឈរឱ្យកៀកនឹងម៉ាស៊ីន អេធីអឹម ហើយយកដៃរបស់អ្នកបាំង នៅពេលដែលកំពុងបញ្ចូលលេខសម្ងាត់ ដើម្បីចៀសវាងការលួចចម្លងលេខសម្ងាត់ពីអ្នកដទៃ។

11.3 Stand close to ATM and always use your hand to shield your PIN when keying in your PIN to avoid others from watching.

១១.៤ លេខសម្ងាត់គឺត្រូវរក្សាការសម្ងាត់បំផុត និងមិនត្រូវបង្ហាញទៅនរណាម្នាក់ទោះក្នុងកាលៈទេសៈណាក៏ដោយ ឬវិធីណាក៏ដោយ ទោះជាមានការស្ម័គ្រចិត្ត ឬផ្សេងពីនេះ។

11.4 The PIN is strictly confidential and shall not be disclosed to any other person under any circumstance or by any means whatsoever whether voluntarily or otherwise.

១១.៥ ប្រសិនបើលោកអ្នកបញ្ចូលលេខសម្ងាត់ខុស បី (៣)ដង នោះលេខសម្ងាត់នៃប័ណ្ណរបស់លោកអ្នកនឹងត្រូវបង្ខាំងដំណើរការ។

11.5 If you incorrectly try your PIN three (3) times, you will be locked out of your card.

១១.៦ ម្ចាស់ប័ណ្ណមិនត្រូវរក្សាទុកកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃលេខសម្ងាត់របស់គាត់នៅកន្លែង ឬវិធីណាមួយដែលអាចឱ្យតតិយជនណាមួយរកឃើញ ដែលនាំឱ្យជននោះប្រើប្រាស់ប័ណ្ណបាន។

11.6 The Cardholder shall not keep any written record of his/her PIN in any place or manner which may enable any third party to make use of the Card.

១១.៧ នៅពេលម្ចាស់ប័ណ្ណទទួលបានលេខសម្ងាត់ វាគឺជាការទទួលខុសត្រូវ របស់ម្ចាស់ប័ណ្ណដើម្បីធានាថាលេខសម្ងាត់មិនត្រូវបានដឹង ឬរកឃើញ ដោយបុគ្គលដទៃទៀត ហើយធនាគារ មិនទទួលខុសត្រូវ ប្រសិនបើលេខសម្ងាត់ត្រូវបានដឹង និងរកឃើញដោយតតិយជន។ ម្ចាស់ប័ណ្ណត្រូវធានាថា ធនាគារមិនជាប់ពាក់ព័ន្ធទៅលើរាល់ការទាមទារ និងការទទួលខុសត្រូវពីគ្រប់ភាគី ដែលកើតឡើងពីការប្រើប្រាស់លេខសម្ងាត់ទោះបីជាមានការអនុញ្ញាត ឬផ្សេងពីនេះ។

១១.៨ ព័ត៌មានប័ណ្ណរបស់លោកអ្នក ដូចជាលេខប័ណ្ណ លេខសម្ងាត់ និងលេខសុវត្ថិភាពជាដើម ត្រូវបានរក្សាទុកជាការសម្ងាត់។ សូមលោកអ្នកជ្រាបថា នឹងមិនមានបុគ្គលិកណាម្នាក់របស់ធនាគារ ទាក់ទងទៅលោកអ្នកដើម្បីស្នើសុំព័ត៌មានសម្ងាត់ទាំងនោះពីលោកអ្នកឡើយ។

11.7 Once the Cardholder receives the PIN, it is the responsibility of the Cardholder to ensure that the PIN is not made known to or easily discovered by any other person as the bank shall not in any way be liable if the PIN is made known to or discovered by any third party. The Cardholder shall hold the bank free from all claims and liabilities from all parties whomsoever arising from the use of the PIN whether authorized or otherwise.

11.8 Your card information is privacy such as card number, PIN and/or security code etc. You shall understand that there is no Woori Bank employee who will communicate with you to ask for your privacy data.

## 12. ការបញ្ចប់ការប្រើប្រាស់ប័ណ្ណដោយម្ចាស់ប័ណ្ណ / Card Termination by Cardholder

១២.១ ម្ចាស់ប័ណ្ណអាចនៅពេលណាមួយ បន្ទាប់ពីការទទួលយក និង/ឬការប្រើប្រាស់ប័ណ្ណ បញ្ចប់ការប្រើប្រាស់ប័ណ្ណដោយជូនដំណឹងជាលាយលក្ខណ៍អក្សរទៅធនាគារ និងប្រគល់ប័ណ្ណនោះមកកាន់ធនាគារ។ នៅពេលធនាគារ បានទទួលប័ណ្ណនោះនឹងត្រូវបានចាត់ទុកថាបានបញ្ចប់ការប្រើប្រាស់ ហើយបញ្ញត្តិទាក់ទងទៅនឹងការបញ្ចប់ការ ប្រើប្រាស់នឹងត្រូវបានអនុវត្ត។

១២.២ ម្ចាស់ប័ណ្ណគឺអ្នកទទួលខុសត្រូវទាំងស្រុងក្នុងការជូនដំណឹងដល់តតិយជនណាមួយ ដើម្បីលុបចោល សេចក្តីណែនាំអំពីការអនុញ្ញាតជាមុនបន្ទាប់ពីមានការបញ្ចប់ការប្រើ ប្រាស់ប័ណ្ណឥណពន្ធ។

១២.៣ មិនមានការបង្វិលសងថ្លៃសេវាប្រចាំឆ្នាំ ឬផ្នែកណាមួយត្រូវបានធ្វើឡើងឡើយ ហើយម្ចាស់ប័ណ្ណនៅតែទទួលខុសត្រូវចំពោះបំណុលទាំងឡាយ សោហ៊ុយកម្រៃការប្រាក់ និង/ឬប្រតិបត្តិការដែល បានធ្វើតាមរយៈប័ណ្ណឥណពន្ធ រួមទាំងការប្រតិបត្តិការ ដែលមិនត្រូវបានកត់ត្រានៅក្នុងគណនីប័ណ្ណឥណពន្ធនៅកាលបរិច្ឆេទនៃការបញ្ចប់ការប្រើប្រាស់ប័ណ្ណ។

12.1 The cardholder may at any time after acceptance and/or usage of the card, terminate the use of the card by a written notice to the bank and returning the card. Upon the bank's receive of the card shall be deemed terminated and the provision relating to determination shall be henceforth applied.

12.2 The cardholder is solely responsible to notify any third party to cancel all pre-authorized standing instructions upon termination of the debit card.

12.3 No refund of annual fee or any part thereof will be made and cardholder shall remain liable for the whole outstanding balance, charges, fees, interest and/or transactions effected through the use of the credit card including uncaptured transaction(s) in the debit card account as of the date of card termination.

## 13. បច្ចុប្បន្នភាពព័ត៌មានរបស់ម្ចាស់ប័ណ្ណ / Updating of The Cardholder's Information

១៣.១ ម្ចាស់ប័ណ្ណ ត្រូវធ្វើការជូនដំណឹងមកកាន់ធនាគារឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ក្នុងករណីមានការផ្លាស់ប្តូរព័ត៌មានរបស់ម្ចាស់ប័ណ្ណ រួមបញ្ចូលទាំងការផ្លាស់ប្តូរអាសយដ្ឋាន លេខទូរស័ព្ទ ឬអាសយដ្ឋានអ៊ីម៉ែល និងមធ្យោបាយទំនាក់ទំនងផ្សេងទៀតដែលធនាគារអាចទាក់ទងម្ចាស់ប័ណ្ណក្រៅពីព័ត៌មានដែលម្ចាស់ប័ណ្ណបានបង្ហាញនៅក្នុងពាក្យ ស្នើសុំប្រើប្រាស់ប័ណ្ណ។

13.1 The cardholder undertakes to notify the bank as soon as practicable of any changes in relation to the cardholder's information including any change of address, telephone number or email address, and any other means of communication by which the bank may communicate with the Cardholder aside from those which have been disclosed in the card application.

## 14. ករណីបាត់ប័ណ្ណ ឬប័ណ្ណត្រូវបានចោរលួច / Theft or Loss of Card

១៤.១ ម្ចាស់ប័ណ្ណ នឹងនៅតែត្រូវតែទទួលខុសត្រូវចំពោះធនាគារ នូវរាល់ទំនិញ និង សេវាកម្មទាំងអស់ដែលបានផ្គត់ផ្គង់ដោយពាណិជ្ជករ និងការដកប្រាក់ដែលកើតឡើងតាមរយៈ ការប្រើប្រាស់ប័ណ្ណ ទោះបីជាការប្រើប្រាស់នោះត្រូវបានឬមិនត្រូវបានអនុញ្ញាតដោយម្ចាស់ប័ណ្ណក៏ដោយ។ ម្ចាស់ប័ណ្ណ ត្រូវមានកាតព្វកិច្ចក្នុងការប្រើប្រាស់ប័ណ្ណដោយមានការយកចិត្តទុកដាក់ ថែរក្សា ការប្រុងប្រយ័ត្នខ្ពស់បំផុត ដើម្បីបង្ការការបាត់បង់ ការលួច ឬការប្រើប្រាស់ ដោយការក្លែងបន្លំ។

១៤.២ ម្ចាស់ប័ណ្ណត្រូវធានាសង និងមិនឱ្យធនាគារ មានការទទួលខុសត្រូវណាមួយចំពោះការបាត់បង់ ការខូចខាត និងចំពោះថ្លៃចំណាយផ្សេងៗ ( ទាំងផ្នែកច្បាប់ឬផ្សេងពីនេះ ) ដែលកើតឡើងពីការបំពាន ឬ មិនគោរពតាមកាតព្វកិច្ចខាងលើរបស់ម្ចាស់ប័ណ្ណ។ កាតព្វកិច្ចក្នុងការប្រើប្រាស់ ដោយមានការយកចិត្តដាក់ ថែរក្សា និងការប្រុងប្រយ័ត្នខ្ពស់បំផុត ដើម្បីបង្ការការបាត់បង់ ការលួច ឬការប្រើប្រាស់ដោយការក្លែងបន្លំរួមមាន៖

( ក ) មិនអនុញ្ញាតឱ្យនរណាម្នាក់ផ្សេងទៀតប្រើប្រាស់ប័ណ្ណ។

( ខ ) មិនត្រូវឱ្យប័ណ្ណឃ្លាតឆ្ងាយពីក្រសែភ្នែករបស់ម្ចាស់ប័ណ្ណ។

១៤.៣ ករណីមានការបាត់បង់ ការលួចប័ណ្ណ ប័ណ្ណត្រូវបានក្លែងបន្លំ ម្ចាស់ប័ណ្ណត្រូវទំនាក់ទំនងទៅផ្នែកសេវាបម្រើអតិថិជន តាមរយៈលេខ ( ៨៥៥ )២៣ ៩៦៣ ៣៣៣ ឬលោកអ្នកអាចបិទដំណើរការប័ណ្ណរបស់អ្នកជាបន្ទាន់តាមរយៈកម្មវិធីធនាគារចល័ត ឬការសសេរបញ្ជាក់ពីហេតុការណ៍នោះជូនដំណឹងដល់ធនាគារ ដោយភ្ជាប់នូវឯកសារថតចម្លងរបស់ប៉ូលីស (របាយការណ៍នៃការបាត់បង់ ឬការលួច ) មិនលើសពីមួយថ្ងៃ គិតចាប់ពីថ្ងៃ ដែលកើតហេតុនៃការបាត់បង់ ឬការលួចប័ណ្ណ ការប្រើប្រាស់ប័ណ្ណគ្មានការអនុញ្ញាត។ ធនាគារនឹងមិនទទួលខុសត្រូវរាល់ការផ្តល់ដំណឹងយឺតទៅលើការបាត់បង់ ឬការលួចប័ណ្ណដោយគ្មានការអនុញ្ញាត។ ប្រសិនបើធនាគារ បានចេញប័ណ្ណថ្មីរួចហើយស្រាប់តែរកឃើញប័ណ្ណដែលបាត់ ឬលួច ម្ចាស់ប័ណ្ណមិនត្រូវប្រើប្រាស់ប័ណ្ណនោះទៀតទេ ត្រូវប្រគល់ទៅធនាគារវិញ។

១៤.៤ ធនាគារ មិនមានកាតព្វកិច្ចចេញប័ណ្ណជំនួសទេ ប៉ុន្តែធនាគារ អាចចេញប័ណ្ណជំនួសបាន លុះត្រាតែម្ចាស់ប័ណ្ណយល់ព្រមនិងទូទាត់ថ្លៃចំណាយឬសោហ៊ុយផ្សេងៗទាក់ទងនឹងការចេញប័ណ្ណជំនួសនេះ ដែលថ្លៃចំណាយ ឬសោហ៊ុយផ្សេងៗ នឹងត្រូវកំណត់ដោយធនាគារ។

14.1 Cardholder shall remain liable to the bank for all goods and services supplied by any merchant and all cash advances effected through the use of the card whether or not such usage is authorized by the Cardholder. The cardholder shall be under a duty to use utmost care, diligence and precautions to prevent the loss, theft or fraudulent use of the Card.

14.2 The cardholder shall indemnify and hold the bank harmless against any liability for losses, damages, costs and expenses (legal or otherwise) arising from the cardholder's breach of such duty. The duty to use utmost care, diligence and precautions to prevent the loss, theft or fraudulent use of the card includes:

(A) Never allowing anyone else to use the card.

(B) Not letting the card out of the cardholder's sight.

14.3 In the event of any loss, theft of the card, card is compromised, cardholder must, contact our call center at (855)23 963 333 or you may freeze/delete your card immediately by using Woori Bank Mobile App or written the confirmation of such event and/or forward us a copy of the police report of the loss, theft of the card no later than one day from the occurrence of such loss, theft, unauthorized use of the card. The bank doesn't take the responsible on the late inform on lost or stolen card. When the lost or stolen card is found, cardholder must not use and return to the bank if the bank already re-issues the new card.

14.4 The bank has no obligation to issue a replacement card, but the bank may do so if the cardholder agrees and pays any costs or other fees related to this card replacement, any costs or fees may be prescribed by the bank.

## 15. ប្រតិបត្តិការវិវាទ / Dispute transaction

១៥.១ រាល់វិវាទដែលកើតឡើងពីប្រតិបត្តិការរបស់ម្ចាស់ប័ណ្ណ ត្រូវជូនដំណឹងមកធនាគារ ក្នុងរយៈពេលដប់ប្រាំ (១៥)ថ្ងៃ ចាប់កាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ក្នុងករណីយឺតយ៉ាវមិនបានជូនដំណឹងឱ្យទាន់ពេលវេលាទេ ធនាគាររក្សាសិទ្ធិមិនដោះស្រាយបញ្ហាជូនឡើយ។

១៥.២ ក្នុងករណីម្ចាស់ប័ណ្ណមានវិវាទ ទាក់ទងនឹងប្រតិបត្តិការដូចដែលមានចែងក្នុងប្រការ ១៥.1 នៃបញ្ញត្តិ និងលក្ខខណ្ឌនេះ ធនាគារមានសិទ្ធិជាឯកតោភាគីកំណត់ពីភាពសមរម្យនៃការបើកការស៊ើបអង្កេត ដោយយោងតាមវិវាទនៃប្រតិបត្តិការ ដូចដែលមានចែងខាងក្រោម៖

(ក) ប្រសិនបើការស៊ើបអង្កេតរបស់ធនាគារ ត្រូវបានរកឃើញ ឬបញ្ជាក់ថាជាប្រតិបត្តិការជារបស់ម្ចាស់ប័ណ្ណ ម្ចាស់ប័ណ្ណត្រូវទទួលខុសត្រូវនូវប្រតិបត្តិការដែលមានវិវាទ។ ធនាគារ មានសិទ្ធិទាមទារថ្លៃសេវានៃការស៊ើបអង្កេត ដប់ភាគរយ (១០%) នៃប្រតិបត្តិការ ឬយ៉ាងតិចដប់ (១០) ដុល្លារអាមេរិក ក្នុងមួយប្រតិបត្តិការវិវាទ។

(ខ) ក្នុងករណីដែលការស៊ើបអង្កេតរកឃើញថា ម្ចាស់ប័ណ្ណមិនមានកំហុស ធនាគារ នឹងមិនគិតថ្លៃស៊ើបអង្កេត។

១៥.៣ ធនាគារ រក្សាសិទ្ធិដោះស្រាយបញ្ហាជូនអតិថិជន ដោយអនុលោមតាមគោលការណ៍ផ្ទៃក្នុង និង/ឬគោលការណ៍ប្រតិបត្តិការអន្តរធនាគារ។ ក្នុងករណីវិវាទណាមួយដែលមិនត្រូវបានដោះស្រាយដោយការចរចានឹងត្រូវដោះស្រាយដោយតុលាការដែលមានសមត្ថកិច្ច ដើម្បីដោះស្រាយតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

15.1 All disputes arising from cardholder's transaction shall be notified to the bank within fifteen (15) days from the date of the transaction. The bank reserves the right not to solve your issue after this period.

15.2 In the event that the cardholder disputes any transaction pursuant to clause 15.1 hereof, the bank may in its absolute discretion deem fit conduct any investigation regarding the dispute transaction wherein the following shall apply:

(A) If the bank investigation reveals or indicates that the cardholder is liable for any of the disputed transaction, the bank shall be entitled to charge ten percent (10%) of dispute amount or minimum ten (10) US Dollars per dispute transaction.

(B) No dispute charge shall be levied in the event that the investigation reveal that the cardholder is not liable for any of the dispute by the bank.

15.3 The bank will reserve the right to remedy the problem in accordance with internal and/or inter-bank transaction regulation. In the case of any dispute that is not settled by amicable negotiation, it will be brought to the competent Cambodia court for settlement according to the laws of Kingdom of Cambodia.

## 16. បង្កាន់ដៃ / Receipts

១៦.១ ម្ចាស់ប័ណ្ណគួរតែទទួលបាន ឬ នឹងទទួលបានព័ត៌មានកត់ត្រាប្រតិបត្តិការនៅពេលអ្នកធ្វើប្រតិបត្តិការរួចរាល់។ ម្ចាស់ប័ណ្ណយល់ព្រមរក្សាព័ត៌មានកត់ត្រាប្រតិបត្តិការរបស់អ្នកដើម្បីផ្ទៀងផ្ទាត់ជាមួយវិក្កយបត្រទិញរបស់អ្នក។លើសពីនេះទៀតម្ចាស់ប័ណ្ណអាចផ្ទៀងផ្ទាត់ប្រតិបត្តិការរបស់អ្នកនៅក្នុងប្រវត្តិប្រតិបត្តិការប័ណ្ណ ជាមួយនឹងវិក្កយបត្រទិញរបស់អ្នក។ ម្ចាស់ប័ណ្ណយល់ព្រមពិនិត្យ និងជូនដំណឹងដល់ធនាគារអំពីកំហុស ភាពមិនប្រក្រតី ភាពមិនស៊ីសង្វាក់គ្នា ការទាមទារ ឬការកាត់ទឹកប្រាក់ដែលមិនមានការអនុញ្ញាត ឬ ប្រតិបត្តិការដែលធ្វើហើយដំណើរការហើយ ឬបានទូទាត់ហើយពីផលនៃការក្លែងបន្លំការក្លែងបន្លំពុំបានផ្តល់សិទ្ធិអំណាចការធ្វេសប្រហែសផ្សេងៗធ្វើឡើងដោយបុគ្គលណាមួយក៏ដោយ។

១៦.២ ម្ចាស់ប័ណ្ណបន្តយល់ព្រមទៀតថាប្រសិនបើអ្នកខកខានក្នុងការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ពួកយើងអំពីកំហុសភាពមិនស្របគ្នាភាពមិនប្រក្រតីឬការកាត់ទឹកប្រាក់ដែលមិនមានការអនុញ្ញាត ឬ ទំនិញក្នុងរយៈពេលដប់ប្រាំ(១៥) ថ្ងៃចាប់ពីថ្ងៃបានធ្វើប្រតិបត្តិការហើយ ឬ ថ្ងៃបានជូនដំណឹងប្រតិបត្តិការសន្មត់ថាម្ចាស់ប័ណ្ណបានទទួលយកនូវកំណត់ត្រាប្រតិបត្តិការនិងសមតុល្យហើយអ្នកនឹងត្រូវបានចាត់ទុកថាបានទទួលយកគ្រប់បញ្ហាទាំងអស់។

16.1 You should get or request an invoice at the time you make a transaction. You agree to retain your invoice to verify your transactions. In addition, you may verify your transactions in the card history against your purchase invoice. You agree to examine and notify us of any errors, irregularities, discrepancies, claims or unauthorized debits or items whether made, processed or paid as a result of forgery, fraud, lack of authority, negligence, or otherwise by any person whatsoever.

16.2 You further agree that if you fail to advise us in writing to notify us of any errors, discrepancies, irregularities, claims or unauthorized debits or items in the statement within fifteen (15) days from, the date of the statement and notification is released, the records shall be conclusive evidence of the transaction entries and balances in such account and you shall be deemed conclusively to have accepted all matters.

## 17. ការរក្សាការសម្ងាត់ / Confidentiality

១៧.១ យើងអាចនឹងផ្តល់ព័ត៌មាននេះទៅភាគីទីបី អំពីប័ណ្ណឥណពន្ធរបស់អ្នក ឬ ប្រតិបត្តិការដែលអ្នកបានធ្វើឡើងដោយប្រើប្រាស់ប័ណ្ណឥណពន្ធ ចំពោះករណី

(ក) ពេលមានភាពចាំបាច់សម្រាប់ការបញ្ចប់ប្រតិបត្តិការ

(ខ) ដើម្បីផ្ទៀងផ្ទាត់ជាមួយលក្ខខ័ណ្ឌរបស់ប័ណ្ណឥណពន្ធ សម្រាប់ភាគីទីបី ដូចជាពាណិជ្ជករ

(គ) ដើម្បីអនុលោមតាមស្ថាប័នរាជរដ្ឋាភិបាល, សេចក្តីសម្រេចតុលាការ ឬតម្រូវការផ្នែកច្បាប់ផ្សេងៗ

(ឃ) អ្នកផ្តល់ការអនុញ្ញាតដល់យើងជាលាយលក្ខណ៍អក្សរ

(ង) ចំពោះនិយោជិត សវនករ ក្រុមបុត្រសម្ព័ន្ធ អ្នកផ្គត់ផ្គង់សេវា ឬ មេធាវីតាមតម្រូវការ។

17.1 We may disclose information to third parties about your debit card or the transactions you make using your Visa debit card:

(A) Where it is necessary for completing transactions;

(B) In order to verify the existence and condition of your debit card for a third party, such as a merchant;

(C) In order to comply with government agency, court order or other legal reporting requirements;

(D) If you give us your written permission;

(E) To our employees, auditors, affiliates, service providers or attorneys as needed.

## 18. ការទទួលខុសត្រូវរបស់យើងចំពោះប្រតិបត្តិការមិនសម្រេច / Our Responsibility for Failure to Complete Transactions

១៨.១ មិនមានករណីណាមួយដែលយើងទទួលខុសត្រូវលើការខូចខាត (រួមមានការបាត់បង់កម្រៃ) ការខូចខាតខ្លាំង ខូចខាតធ្ងន់ធ្ងរនោះឡើយ។ យើងនឹងមិនទទួលខុសត្រូវក្នុងករណីដូចជា

(ក) មិនមែនជាកំហុសរបស់យើង ដោយសារអ្នកមិនមានសមតុល្យគ្រប់គ្រាន់ដើម្បីបញ្ចប់ប្រតិបត្តិការនោះ

(ខ) អ្នកផ្គត់ផ្គង់ផលិតផល ឬសេវាមិនទទួលយកការទូទាត់តាមប័ណ្ណឥណពន្ធ ឬមិនព្រមសងប្រាក់អ្នកវិញ

(គ) ប្រសិនបើម៉ាស៊ីនទូទាត់នោះ មិនដំណើរការត្រឹមត្រូវ ឬមានភាពមិនប្រក្រតី ហើយអ្នកក៏បានដឹងពីបញ្ហានេះមុនធ្វើប្រតិបត្តិការនេះដែរ

(ឃ) ប្រសិនបើប័ណ្ណឥណពន្ធរបស់អ្នកត្រូវបានបិទមិនឱ្យប្រើបាន បន្ទាប់ពីអ្នកបានជូនដំណឹងថាប័ណ្ណនោះត្រូវបានគេលួច ឬបាត់

18.1 In no event will we be liable for consequential damages (including lost profits), extraordinary damages, special or punitive damages. We will not be liable, for instance:

(A) If, through no fault of ours, you do not have enough funds available in your account to complete the transaction;

(B) If a merchant refuses to accept your debit card or provide cash back;

(C) If an electronic terminal where you are making a transaction does not operate properly, and you knew about the problem when you initiated the transaction;

(D) If your debit card has been blocked after you reported lost or stolen;

(ង) ប្រសិនបើមានប្រាក់បង្កក ឬប្រាក់នោះត្រូវមានចំណាត់ការផ្លូវច្បាប់ ឬបន្ទុកកំណត់ក្នុងការប្រើប្រាស់ផ្សេងទៀត

(ច) ប្រសិនបើយើងពិនិត្យឃើញថាប្រតិបត្តិការរបស់អ្នកធ្វើឡើងដោយខុសច្បាប់

(ឆ) ករណីប្រធានស័ក្តិកើតមានឡើងដែលហួសពីសមត្ថភាពគ្រប់គ្រងរបស់យើង (ដូចជាអគ្គិភ័យ, ទឹកជំនន់, កុំព្យូទ័រ ឬទំនាក់ទំនងមិនដំណើរការ) រាំងស្ទះមិនឱ្យប្រតិបត្តិការបានជោគជ័យ

(ជ) ករណីលើកលែងផ្សេងទៀតដែលបានធ្វើជាមួយអ្នកក្នុងកិច្ចព្រមព្រៀងនេះ។

(E) If there is a hold or your funds are subject to legal process or other encumbrance restricting their use;

(F) If we have reason to believe the requested transaction is unauthorized;

(G) If circumstances beyond our control (such as fire, flood or computer or communication failure) prevent the completion of the transaction, despite reasonable precautions that we have taken;

(H) For any other exception stated in our Agreement with you.

## 19. ការកែប្រែ បទបញ្ញត្តិ និងលក្ខខណ្ឌ / Revision of terms and conditions

១៩.១ ធនាគារ អាចបន្ថែម ឬផ្លាស់ប្តូរបញ្ញត្តិ និងលក្ខខណ្ឌទាំងនេះ ពីពេលមួយទៅពេលមួយ ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់ប័ណ្ណយ៉ាងហោចណាស់ សាមសិប (៣០) ថ្ងៃប្រតិទិនជាមុន ធ្វើការកែប្រែ ឬផ្លាស់ប្តូរបញ្ញត្តិ និងលក្ខខណ្ឌទាំងនេះ។

១៩.២ ការកែប្រែ ឬផ្លាស់ប្តូរបញ្ញត្តិ និងលក្ខខណ្ឌទាំងនេះ នឹងត្រូវបានធ្វើការជូនដំណឹងទៅម្ចាស់ប័ណ្ណ តាមរយៈការផ្ញើសារ ឬ សារអេឡិចត្រូនិក ឬ កម្មវិធីធនាគារចល័ត ឬ បង្ហាញសេចក្តីជូនដំណឹងជាសាធារណៈតាមសារព័ត៌មាន ឬ សាខាធនាគាររបស់យើង ឬ លើគេហទំព័ររបស់ធនាគារ។

១៩.៣ ការរក្សាទុកឬការប្រើប្រាស់ប័ណ្ណបន្ទាប់ពីកាលបរិច្ឆេទដែលការកែប្រែឬផ្លាស់ប្តូរបញ្ញត្តិនិងលក្ខខណ្ឌ ដូចដែលមានចែងក្នុងប្រការ ១៩.១ ត្រូវបានចាត់ទុកថាជាការទទួលយកនូវការកែប្រែ ឬ ផ្លាស់ប្តូរបញ្ញាត្តិ និងលក្ខខណ្ឌទាំងនេះ។

១៩.៤ ប្រសិនបើម្ចាស់ប័ណ្ណមិនទទួលយកការកែប្រែ ឬផ្លាស់ប្តូរបញ្ញត្តិ និងលក្ខខណ្ឌទាំងនេះ ម្ចាស់ប័ណ្ណត្រូវបញ្ឈប់ការប្រើប្រាស់ប័ណ្ណ តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅធនាគារ ពីការបញ្ឈប់ការប្រើប្រាស់ប័ណ្ណ។

19.1 The bank may revise or change terms and conditions from time to time by giving written notice to cardholder of at least thirty (30) calendar days in advance before the bank shall revise or change the terms and conditions.

19.2 Variation or change of the terms and conditions shall be sent by SMS or Email or Mobile App or posting on newspaper or branch offices or Woori Bank website.

19.3 Retention or use of the card after the effective date of any variation, or change of terms and conditions pursuant to clause 19.1 hereof shall be acceptance of variation or change of terms and conditions.

19.4 If the cardholder does not accept the proposed variation or change terms and conditions, cardholder must terminate the use of card by giving written notice to the bank.

## 20. មិនមានការធានាចំពោះផលិតផល និងសេវា / No Warranty Regarding Goods and Services

២០.១ យើងមិនទទួលខុសត្រូវលើគុណភាព, សុវត្ថិភាព, ភាពស្របច្បាប់ ឬ លក្ខណសម្បត្តិផ្សេងទៀតនៃផលិតផល ឬសេវាដែលអ្នកបានទិញដោយប្រើប្រាស់ប័ណ្ណឥណពន្ធរបស់អ្នកឡើយ។ អ្នកត្រូវទទួលខុសត្រូវដោយខ្លួនឯង ក្នុងការពិនិត្យនិងផ្ទៀងផ្ទាត់ជាមួយអ្នកផ្គត់ផ្គង់ផលិតផលនិងសេវាកម្ម ដើម្បីធានាថា អ្នកទទួលបានផលិតផលនិងសេវាតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងទិញលក់ជាមួយអ្នកលក់។

20.1 We are not responsible for the quality, safety, legality or any other aspects of any goods or services you purchase with your debit card. It is your responsibility to check and work with merchant to ensure that you get goods and service as agreed in the purchased term.

## 21. ការប្រឆាំងនឹងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងការដាក់ទណ្ឌកម្ម / Anti-Money Laundering, Terrorist Financing and Sanctions Controls

២១.១ ម្ចាស់ប័ណ្ណយល់ព្រមថាធនាគារ អាចពន្យារ បិទ ឬបដិសេធនូវដំណើរការនៃប្រតិបត្តិការណាមួយ ដោយរួចផុតពីការទទួលខុសត្រូវផ្សេងៗ ប្រសិនបើធនាគារ សង្ស័យថា៖

(ក) ប្រតិបត្តិការនោះអាចបំពានច្បាប់ ឬបទបញ្ញត្តិណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ប្រទេសដទៃទៀត

(ខ) ប្រតិបត្តិការពាក់ព័ន្ធនឹងបុគ្គលណាមួយ (រូបវន្តបុគ្គលនីតិបុគ្គលឬរាជរដ្ឋាភិបាល) ដែលប្រតិបត្តិការនៃបុគ្គលនោះ ឬប្រតិបត្តិការនោះពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលទៅនឹងបុគ្គលដទៃទៀត ដែលប្រតិបត្តិការរបស់បុគ្គលនោះស្ថិតនៅក្រោមទណ្ឌកម្មសេដ្ឋកិច្ចឬពាណិជ្ជកម្មដែលកំណត់ដោយសហរដ្ឋអាមេរិក សហគមន៍អឺរ៉ុប ឬប្រទេសដទៃទៀត

(គ) ប្រតិបត្តិការអាចពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលជាមួយ នឹងដំណើរការ ឬតម្រូវតាមគោលបំណងនៃការធ្វើប្រតិបត្តិការ ដែលខុសទៅនឹងច្បាប់នៃប្រទេសកម្ពុជា ឬប្រទេសដទៃទៀត។

21.1 The Cardholder agrees that the bank may delay, block or refuse to process any transaction without incurring any liability if the bank suspects that:

(A) The transaction may breach any laws or regulations in the Kingdom of Cambodia or any other country;

(B) The transaction involves any person (individual, legal entity or governmental) that is itself sanctioned or is connected, directly or indirectly, to any person that is sanctioned under economic and trade sanctions imposed by the United States, the European Union or any country;

(C) The transaction may directly or indirectly involve the proceeds of, or be applied for the purposes of, conduct which is unlawful in Cambodia or any other country.

## 22. ការប្រាស្រ័យទាក់ទង / Communication

២២.១ ប្រសិនបើលោកអ្នកមានសំណួរណាមួយពាក់ព័ន្ធនឹងប័ណ្ណឥណពន្ធ លោកអ្នកអាចទំនាក់ទំនង (៨៥៥)២៣ ៩៦៣ ៣៣៣។ ធនាគារ នឹងដោះស្រាយសំណួររបស់លោកអ្នកភ្លាមៗ។

22.1 If you have an enquiry relating to your debit card, you can contact us via (855)23 963 333. We will deal with your enquiry promptly.

## 23. លក្ខខណ្ឌផ្សេងៗ / Other Conditions

២៣.១ បញ្ញាត្តិនិងលក្ខខណ្ឌរបស់ធនាគារត្រូវបានចែងជាភាសាខ្មែរនិងភាសាអង់គ្លេសក្នុងករណីមានភាពមិនស្របគ្នាណាមួយ ឯកសារជាភាសាខ្មែរ នឹងត្រូវយកធ្វើជាគោល។

២៣.២ បញ្ញាត្តិ និងលក្ខខណ្ឌនេះ ត្រូវអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

២៣.៣ ខ្ញុំបានអាន និងយល់នូវរាល់ព្រមបញ្ញាត្តិ និងលក្ខខណ្ឌទាំងឡាយដូចមានចែងខាងលើនេះ។

23.1 To extent that Khmer version of any document including these terms and conditions is inconsistent with English version, the terms and conditions of Khmer version shall prevail.

23.2 The laws of Kingdom of Cambodia govern these terms and conditions.

23.3 Hereby have read and accepted all these terms and conditions as mentioned above.

**ធនាគារ អ៊ូរី (ខេមបូឌា) ម.ក | Woori Bank (Cambodia) Plc.**

អាគារលេខ ៣៩៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងកេងកងទី ១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ

Building No. 398, Preah Monivong Blvd., Sangkat Boeng Keng Kang 1,

Khan Boeng Keng Kang, Phnom Penh. (+855) 23 96 33 33 | 81 331 333